# ជីវិត Life

"ខ្ញុំមកដើម្បីឲ្យមនុស្សលោកមានជីវិត ហើយឲ្យមាន
ជីវិតយ៉ាងបរិបូរណ៍"។

( យ៉ូហាន:១០,១០)

សកម្មភាពព្រះសហគមន៍ភូមិភាគភ្នំពេញ

លេខ៦ សម្រាប់ ថ្ងៃទី០១-៣១ ខែឧសភា ឆ្នាំ២០១២

## អបអរសាទរពិធីបុណ្យព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ



**អេម៉ានូអែល**

សំឡេងព្រះសហគមន៍កាតូលិក **FM 102.5 Mhz**

ម៉ោង ២:០០ - ៣:០០ រាល់ថ្ងៃសុក្រ

**ខ្ញុំត្រូវការអ្នក (I NEED YOU)**

រាល់ថ្ងៃច័ន្ទ និងអង្គារ **FM 99.5 Mhz**

ម៉ោង ១០:០០ - ១១:០០ ព្រឹក

## សារជូនពរ ដល់គ្រីស្តបរិស័ទ របស់លោកអភិបាលអូលីវីយេ
## ក្នុងឱកាសបុណ្យចូលឆ្នាំថ្មី ប្រពៃណីខ្មែរ ឆ្នាំរោង ចត្វាស័ក
## ពុទ្ធសករាជ ២៥៥៦ ត្រូវនឹងគ្រីស្តសករាជ ២០១២

**បងប្អូនជាទីស្រឡាញ់!**

សួស្តីឆ្នាំថ្មី ឆ្នាំរោង ចត្វាស័ក ពុទ្ធសករាជ ២៥៥៦ !

ឆ្នាំថ្មីនេះ ចាប់ផ្តើមដោយដំណឹងល្អមួយគឺព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញហើយ! ព្រះជាម្ចាស់បានប្រោសព្រះយេស៊ូឲ្យក្រោកឈរឡើងពីចំណោមមនុស្សស្លាប់! ជីវិតបានឈ្នះសេចក្តីស្លាប់ហើយ គឺឈ្នះជារហូតដរាបតរៀងទៅ។ ដំណឹងល្អនេះជាស្នូលនៃជំនឿរបស់យើង ហើយជំរុញយើងឲ្យធ្វើជាសាក្សីអំពីសេចក្តីសង្ឃឹមនេះ ដែលបានផ្លាស់ប្រែទ្រង់ទ្រាយនៃផែនដី។

នៅពេលព្រឹកថ្ងៃបុណ្យចម្លង ស្ត្រីៗរត់ទៅចែកដំណឹងស្តីអំពីផ្នូរនៅទទេ គ្រីស្តទូតក៏រត់ទៅឃើញអ្វីៗដែលកើតឡើងនោះ។ តើព្រះសពព្រះយេស៊ូបាត់ទៅណា? សាវ័កដែលព្រះយេស៊ូស្រឡាញ់ចូលទៅក្នុងផ្នូរ *គាត់ឃើញហើយជឿ*។

**បងប្អូនជាទីស្រឡាញ់!**

នៅប្រទេសកម្ពុជាយើងនេះ ព្រះជាម្ចាស់បានផ្ញើទុកជំនឿនេះឲ្យយើង។ តាំងពីប៉ុន្មានតំណមក ជំនឿនេះធ្វើឲ្យមនុស្សអាចរើភ្នំពីកន្លែងរបស់ខ្លួនបាន។

ចូរមានមោទនភាពនិងមានកិត្តិយសឡើង ដោយសារយើងជាសាវ័ករបស់ព្រះគ្រីស្ត។

*យើងមានមោទនភាពនិងមានកិត្តិយស ពីព្រោះយើងជាបុត្រធីតារបស់ព្រះជាម្ចាស់!*

*យើងមានមោទនភាពនិងមានកិត្តិយស ពីព្រោះព្រះជាម្ចាស់ចងសម្ពន្ធមេត្រីជាមួយយើងម្នាក់ៗ។*

*យើងមានមោទនភាពនិងមានកិត្តិយស ពីព្រោះនៅពេលព្រះជាម្ចាស់ប្រោសឲ្យព្រះយេស៊ូរស់ឡើងវិញ ព្រះអង្គក៏ប្រោសឲ្យយើងអាចទទួលព្រះជន្មផ្ទាល់របស់ព្រះអង្គដែរ គឺជាព្រះជន្មស្ថិតស្ថេរនៅជានិច្ចនិរន្តរ៍។*

មោទនភាពរបស់យើង ហូរមកពីព្រះយេស៊ូស្លាប់លើឈើឆ្កាងជាឈើសម្រាប់ធ្វើទារុណកម្ម តែព្រះជាម្ចាស់បានផ្លាស់ប្រែឈើនេះ ឲ្យទៅជាឈើដែលផ្តល់ជីវិតវិញ។ នៅលើឈើឆ្កាង ព្រះយេស៊ូបណ្តោយឲ្យគេបន្ទាបបន្ថោកព្រះអង្គ។ គេលះបង់ព្រះអង្គគ្រប់គ្នា តែព្រះយេស៊ូនៅតែស្រឡាញ់មនុស្សលោកដោយប្រទាននាងម៉ារីឲ្យមនុស្សលោកទុកជាមាតា។ ព្រះអង្គនៅតែលើកលែងទោស ដោយសុខចិត្តទទួលចោរព្រៃឲ្យនៅជាមួយព្រះអង្គនៅស្ថានបរមសុខនៅថ្ងៃនោះ។

ព្រះជាម្ចាស់ប្រោសព្រះយេស៊ូឲ្យរស់ឡើងវិញ តែព្រះយេស៊ូបានបង្រៀនឲ្យយើងបម្រើគេ ឲ្យយើងយកកន្លែងនិងមុខងារថោកជាងគេបំផុត ឲ្យយើងលីឈើឆ្កាងរបស់យើង ឲ្យយើងលះបង់ខ្លួនឯងដើម្បីឲ្យយើងបានជីវិត។ នៅពេលព្រឹកនៃថ្ងៃបុណ្យចម្លងនេះ យើងយល់ឃើញថាជីវិតនេះ គឺជាព្រះជន្មរបស់ព្រះជាម្ចាស់ផ្ទាល់។ យើងមិន

ទាន់ស្គាល់ជីវិតថ្មីនេះទេ តែយើងត្រៀមខ្លួននឹងទទួល ដោយរស់នៅនិងដោយស្រឡាញ់ ដូចព្រះយេស៊ូបានរស់នៅ និងបានស្រឡាញ់ដូច្នោះដែរ។

ព្រះសហគមន៍នៅប្រទេសកម្ពុជាយើង បានទទួលជំនឿលើព្រះយេស៊ូដែលមានព្រះជន្មរស់ឡើងវិញ ទុកជាកេរមត៌កពីដូនតាមក។ របបប្រល័យពូជសាសន៍របស់ប៉ុលពតបានបង្ហាញបញ្ជាក់ថា គ្រាប់ពូជនៃជំនឿដែលដូនតាបានសាបព្រោះនោះ មានជីវិតរស់រវើកហើយ។ ព្រះសហគមន៍ជិតវិនាសសាបសូន្យហើយ តែឈាមអភិបាលខ្មែរយើង ឈាមបូជាចារ្យខ្មែរយើង ឈាមបងប្អូនខ្មែរយើង ឈាមរបស់អ្នកទទួលអគ្គសញ្ញាជ្រមុជទឹករាប់រយនាក់ ត្រូវគេបង្ហូរដើម្បីឲ្យស្រែរបស់យើង ពោលគឺព្រះសហគមន៍របស់យើង បានបង្កើតផលជាដរាបតរៀងទៅ។

ព្រះសហគមន៍ មានជីវិតរស់រវើក ដោយសារអស់អ្នកដែលបានបូជាជីវិតដោយចិត្តស្រឡាញ់។

**បងប្អូនជាទីស្រឡាញ់ !**

ចូរមានមោទនភាពនិងមានកិត្តិយសឡើង ដោយសារយើងជាសមាជិកនៃព្រះសហគមន៍នៅប្រទេសកម្ពុជា!

*យើងមានមោទនភាពនិងមានកិត្តិយសពីព្រោះយើងធ្វើឲ្យព្រះជាម្ចាស់មានវត្តមានក្នុងប្រទេសយើង គឺមានវត្តមានក្នុងអំណរសប្បាយនិងក្នុងទុក្ខព្រួយរបស់ ប្រជាជននៃជនរួមជាតិយើង។*

*យើងមានមោទនភាពនិងមានកិត្តិយស ពីព្រោះឈាមនៃមរណសាក្សីរបស់ព្រះសហគមន៍យើង ផ្តល់ជីវិតរស់រវើកដល់សហគមន៍នានារបស់យើង។*

*យើងមានមោទនភាពនិងមានកិត្តិយសពីព្រោះព្រះជាម្ចាស់ទុកព្រះហឫទ័យលើយើង គឺព្រះអង្គធ្វើឲ្យយើងណែនាំបងប្អូនរួមជាតិ ឲ្យស្គាល់និងស្រឡាញ់ព្រះអង្គ។*

ដំណឹងល្អនៃបុណ្យចម្លង ជំរុញយើងឲ្យលែងភ័យខ្លាចទៀតហើយ។ យើងហ៊ានប្រកាសជំនឿ ហើយយើងត្រូវតែជាគ្រីស្តបរិស័ទដែលមានសេចក្តីក្លាហានឡើង!

យើងត្រូវតែបង្ហាញឲ្យគេដឹងថា យើងស្រឡាញ់ព្រះសហគមន៍របស់យើង ដោយចូលរួមយ៉ាងសកម្មក្នុងពិធីបុណ្យនានា និងរួមសកម្មភាពផ្សេងៗតាមព្រះវិហាររបស់យើង។

យើងត្រូវតែបង្ហាញឲ្យគេដឹងថា ព្រះយេស៊ូពិតជាជីវិតរបស់យើង ដោយយើងធ្វើជាសាក្សីបញ្ជាក់ថា ព្រះជាម្ចាស់មានព្រះហឫទ័យមេត្តាករុណាស្រឡាញ់មនុស្សទាំងអស់។

យើងត្រូវតែបង្ហាញឲ្យគេដឹងថា ព្រះសហគមន៍ដ៏តូចនៅប្រទេសកម្ពុជាយើង តាមពិតជាព្រះសហគមន៍ដ៏ធំ ដោយសារកម្លាំងនៃជំនឿរបស់យើង និងដោយសារយើងខ្នះខ្នែងស្រឡាញ់គេព្រមទាំងមានអំណរសប្បាយ មកពីសេចក្តីសង្ឃឹមរបស់យើង។ ពិតមែនហើយ យើងត្រូវតែមានមោទនភាព! និងមានអំណរសប្បាយឡើង!

**ប្រទេសខ្ញុំ! ព្រះសហគមន៍ខ្ញុំ!**

***ខ្ញុំសូមអញ្ជើញបងប្អូនទាំងអស់ មកលើកតម្កើងមរណសាក្សីរបស់យើងនៅថ្ងៃសៅរ៍ ទី ៥ ខែឧសភា វេលា ម៉ោង ៩ : ៣០ នៅ តាំងគោក ដើម្បីយើងសម្តែងសេចក្តីស្រឡាញ់ចំពោះព្រះសហគមន៍របស់យើង។***

សួស្តីឆ្នាំថ្មី! សូមព្រះជាម្ចាស់ប្រទានពរឲ្យអស់បងប្អូន គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូមព្រះបិតាប្រទានសេចក្តីសុខសាន្ត ឲ្យអស់បងប្អូន និងញាតិសន្តាន មិត្តជិតឆ្ងាយរបស់បងប្អូន។

សូមឲ្យរដូវបុណ្យចម្លងនេះ ទៅជារដូវទទួលជីវិតយ៉ាងពេញបរិបូរណ៍។

APOSTOLIC VICARIATE PHNOM PENH

\+ អូលីវីយេ
អភិបាលរបស់បងប្អូន

# លោកបូជាចារ្យឡេវ៉ាន់ទីន មានមុខងារជាអ្នកទទួលខុសត្រូវមណ្ឌលសកម្មភាពទន្លេបាសាក់





លោកបូជាចារ្យ ឡេ វ៉ាន់ទីន ត្រូវបានលោកអភិបាលចាត់ឲ្យទទួលមុខងារជាអ្នកមើលការខុសត្រូវមណ្ឌលសកម្មភាពទន្លេបាសាក់។

លោកឪពុកឡេវ៉ាន់ទីន ត្រូវទៅស្នាក់នៅព្រះសហគមន៍ជ្រៃធំ ហើយលោកនឹងទទួលបន្ទុកមើលការខុសត្រូវព្រះសហគមន៍ចំនួន៦គឺៈ ព្រះសហគមន៍ជ្រៃធំ ព្រះសហគមន៍សំប៉ាន់ ព្រះសហគមន៍កោះទាវ ព្រះសហគមន៍ស្អាង ព្រះសហគមន៍បឹងឈូក និង ព្រះសហគមន៍ទួលក្រសាំង។

មណ្ឌលសកម្មភាពចំប៉ាត្រូវបានបែងចែកជាពីរគឺ មណ្ឌលសកម្មភាពទន្លេមេគង្គ និង មណ្ឌលសកម្មភាពទន្លេបាសាក់។

លោកបូជាចារ្យឡេ វ៉ាន់ទីន ធ្លាប់ទទួលបន្ទុកណែនាំព្រះសហគមន៍មណ្ឌលចំប៉ា។ ដោយសារលោកមានបន្ទុកធ្ងន់ក្នុងការមើលខុសត្រូវព្រះសហគមន៍នីមួយៗទើប លោកអភិបាលបានបែងចែកជាពីរមណ្ឌលដើម្បីឲ្យលោកឪពុក វិរៈជ័យ ជួយសម្រាលការងារ។

## Fr. Levan Tin Comes to Lead Tonle Bassac Pastoral Center

Fr. Le Van Tinh is now in charge of Tonle Basac Pastoral Center. A grand official welcome ceremony presided by Bishop Olivier was held for him at Chrey Thom parish on March 29, 2012.

As Champa pastoral center was divided into two -- Tonle Basac and Tonle Mekong -- Fr. Le Van Tinh will take care of the first pastoral center which consists of 6 parishes: Chrey Thom, Sampan, Koh Tiev, Saang, Boueng Chhouk, and Toul Krasang.

Mr. Sang, youth leader in Champa parish, said that Fr. Tinh is "a good priest and he always helps the poor." He added that the Catholic community in Champa has been saddened by Fr. Tin's departure since they thought that Fr. Tinh would be with them till his retirement. " He has been here for over 20 years. He has left us a lot of unforgettable memories," said Mr. Sang.



## Fr. Mario takes over new pastoral Center—Boeung Tumpun

Fr. Mario Ghezzi in charge North Phnom Penh Pastoral Center which consist of three parishes: Boeung Tum Pun, Koh Noria, and Tu Taing.

លោកមារីយ៉ូត្រូវបានលោកអភិបាលប្រគល់មុខងារជាអ្នកទទួលខុសត្រូវលើមណ្ឌលសកម្មភាពភ្នំពេញខាងត្បូង ដែលមានព្រះសហគមន៍ចំនួនបីគឺ ព្រះសហគមន៍បឹងទំពុន, កោះនរា និងព្រះសហគមន៍ តួតាំង។

## ព្រះសហគមន៍បឹងទំពុនផ្តល់អំណោយជូនគ្រួសារក្រីក្រ

គ្រួសារចំនួន៤៥គ្រួសារបានទទួលអំណោយពីព្រះសហគមន៍ព្រះកុមារយេស៊ូបឹងទំពុនកាលពីមីនាកន្លងទៅនេះ។

ក្នុងគ្រួសារនីមួយៗទទួលបានអង្ករ មី ទឹកស៊ីអ៊ីវ ទឹកត្រី ស្ករ សាប៊ូ និងសំលៀកបំពាក់មួយចំនួន។

លោកស្រី សំអ៊ុន ជាគណកម្មការមានប្រសាសន៍ថា ប្រាក់ និងអង្ករដែលបានចែកជូនដល់គ្រួសារអ្នកក្រីក្រទាំងនោះភាគច្រើនគឺបានមកពីការចូលរួមវិភាគទានរបស់គ្រីស្តបរិស័ទក្នុងរដូវរង់ចាំ និងបុណ្យព្រះយេស៊ូប្រសូត្រ។ លោកស្រីបានបន្ថែមថា ព្រះសហគមន៍បឹងទំពុនមានកម្មវិធីផ្តល់អំណោយដល់គ្រួសារក្រីក្រយ៉ាងហោចណាស់ពីរដងក្នុងមួយឆ្នាំ។ អ្នកក្រីក្រទាំងនោះមកពីបណ្តាភូមិដូចជាព្រែកតាគង់(ចាក់អង្រែលើ) បឹងទំពុន បឹងត្របែក និងស្ទឹងមានជ័យ។

## Boeng Tum Pun parish donates 45 families

Forty five families received donation from Child Jesus Parish (Boeng Tumpun) last March. Each family was provided rice, noodles, soy sauce, sugar, soap, shampoo and some clothes.

Mrs. Som Un, a charity commitee member, said that money and stuff that have been given to the poor families were from the collection during the Advent and Christmas seasons. She added that the Church has done this project at least two times for the poor families who normally come from neighboring villages in Phnom Penh.





# មណ្ឌលសកម្មភាពកំពតទទួលការអប់រំអំពីព្រះគម្ពីរដំណឹងល្អតាមលោកម៉ាកុស

មានគ្រីស្តបរិស័ទជាច្រើននាក់បានចូលរួមសំណាក់ធម៌អំពីព្រះគម្ពីរដំណឹងល្អតាមលោកម៉ាកុសនៅថ្ងៃទី១ ខែមេសាកន្លងទៅនេះ។

តាមរយៈព្រះគម្ពីរលោកម៉ាកុស លោកអភិបាលអូលីវីយេបានលើកយកចំនុច៤សំខាន់ៗ។ ទីមួយគឺ ព្រះយេស៊ូយាងមកក្នុងពិភពលោកដើម្បីប្រកាសអំពីព្រះរាជ្យរបស់ព្រះជាម្ចាស់។ ទីពីរ ព្រះយេស៊ូជានណា។ ទីបី តើយើងស្វាគមន៍ព្រះយេស៊ូយ៉ាងដូចម្តេចក្នុងជីវិតរបស់យើង?។ចុងបញ្ចប់គឺព្រះយេស៊ូប្រទានពន្លឺដល់អស់អ្នកដែលដើរតាមព្រះអង្គ។ លោកអភិបាលបានពន្យល់ថា យើងម្នាក់ៗអាចស្វាគមន៍ព្រះយេស៊ូតាមរបៀបបីយ៉ាងគឺ ការធ្វើឲ្យចិត្តយើងបរិសុទ្ធ ការចេះលះបង់ចោលអំពើអាក្រក់ និងយើងត្រូវដាក់ខ្លួនជាអ្នកក្រីក្រ។

លោកហ្វេណាន់ដូ មានប្រសាសន៍ថា បងប្អូនគ្រីស្តបរិស័ទបានទទួលយកការអប់រំរបស់លោកអភិបាលដោយអំណរ។ លោកបន្តទៀតថា បងប្អូនគ្រីស្តស័ទមួយចំនួនធំនៅតាមព្រះសហគមន៍មានការផ្លាស់ប្តូរ និងយល់បានច្រើនជាងមុនអំពីជំនឿ និងការរស់នៅ។

## Recollection about Bible according to St. Mark at Kompot

Catholics in Kompot pastoral Center came for recollection, led by Bishop Olivier on April1. There are four important points that Bishop has mentioned according to St. Mark. Firstly, Jesus came to proclaim to Kingdom of God. Secondly, Who is Jesus? Thirdly, how do you welcome Jesus in our life? Finally, Jesus give light to those who want to follow him.

Bishop Olivier explained that we can welcome Jesus with three ways: the purity of heart, the abandon sins and poverty.

Fr. Fernando said that the recollection was a very great moment for the Catholics to understand deeply about their faith and lives. He noticed that after they received a talk from Bishop, they are more likely interested and spend more time to the church.










# សំណាក់ធម៌ជំហានទីមួយនៅចំការទៀង

បេក្ខជនជំហានទី១ ចំនួន ៧២នាក់ មកពីមណ្ឌលសកម្មភាពតាកែវបានមកចូលរួមសំណាក់ធម៌ដែលដឹកនាំដោយលោកអភិបាលអូលីវីយេកាលពីថ្ងៃទី១៨-១៩កន្លងទៅនេះនៅព្រះវិហារសន្តីម៉ារីញញឹម ចំការទៀង។

កម្មវិធីសំណាក់ធម៌នេះមានគោលបំណងដើម្បីឲ្យបងប្អូនដែលទើបតែនឹងស្គាល់ព្រះសហគមន៍អាចយល់ច្បាស់អំពីជំនឿកាតូលិក។

ក្នុងកម្មវិធីសំណាក់ធម៌នោះប្រព្រឹត្តទៅដោយមានការចូលរួម២១នាក់មកពីសន្តប៉ូល ១៣នាក់មកពីព្រៃកប្បាស និង៣៨នាក់មកពីចំការទៀង។

យុវសិស្ស ពន្លក មកពីព្រះសហគមន៍ព្រៃកប្បាសបាននិយាយថា គេពិតជាពេញចិត្តនឹងទទួលយកជំនឿតាមបែបកាតូលិកទោះបីជាមានតែម្នាក់ឯងក្នុងគ្រួសារក៏ដោយ។ ប្អូនប្រុសរូបនេះបានបន្តទៀតថា នៅពេលអ្នកដទៃនិយាយអាក្រក់អំពីសាសនាគ្រីស្ត គ្រួសាររបស់គេតែងតែមានការព្រួយបារម្ភ។ ប្អូនពន្លកបានរៀបរាប់ថា កាលពីមុនគេក៏ធ្លាប់យល់ច្រឡំដូចគេទាំងនោះដែរ។ ពន្លកក៏បានឲ្យដឹងទៀតថា គ្រួសាររបស់គេមានការបារម្ភជាខ្លាំង នៅពេលដែលខ្លួនសម្រេចចិត្តស្វែងយល់ពីជំនឿតាមបែបកាតូលិក។ ប៉ុន្តែពេលនេះពួកគាត់បានយល់ ទោះបីជាគេមិនទាន់សម្រេចចិត្តទទួលយកជំនឿនេះក៏ដោយ។ ប្អូនប្រុសបានបញ្ជាក់ថា ឥឡូវនេះខ្លួនហាក់បីដូចជាមានពន្លឺមួយដែលជួយបំភ្លឺជីវិត។

មណ្ឌលសកម្មភាពតាកែវ បានបង្កើតព្រះសហគមន៍ថ្មីចំនួនពីរទៀតគឺ ព្រះសហគមន៍ ព្រៃកប្បាស និងព្រះសហគមន៍សន្តប៉ូល។

## 72 Candidates Come for Retreat at Chamka tieng.

72 candidates from the Takeo Pastoral Center gathered at the Chamka Tieng Parish last March 18-19 2012 for the retreat animated by Bishop Olivier in preparation to the first step prior to baptism.

Of these 72 candidates, 21 came from St. Paul Parish, 13 from Prey Kabas, and 38 from Chamka Tieng. St. Paul and Prey Kabas are two new parishes in Takeo.

Mr. Ponlok, from Prey Kabas said that he was very excited to follow the Catholic faith even he is the only one to be baptized in his family. "My family and I used to feel negatively towards Christianity, but now I realize that this religion is a light in my life," Ponlok said.

# លោកបូជាចារ្យអ៊ុន សុនះ ព្រះយេស៊ូគ្រីស្ត មានព្រះជន្មថ្មីដ៏រុងរឿងប្រទានជីវិតឲ្យយើង



ក្នុងឱកាសបុណ្យចម្លងព្រះសហគមន៍តំបន់ព្រះសីហនុ មានពិធីជ្រមុជទឹក ឲ្យបេក្ខជន ១៧នាក់ មានកូនង៉ា ៩នាក់ ហើយនារីៗជំទង់ ៨នាក់។ រាត្រីនៃបុណ្យចម្លងនេះបានធ្វើឲ្យយើងមានអំណរសប្បាយរីករាយ រំភើបក្រៃលែង។ ក្នុងពិធីបុណ្យ មានចែកជា ៤ ដំណាក់កាលគឺ៖ ទីមួយ គោរពព្រះគ្រីស្តជាពន្លឺបំភ្លឺមនុស្សលោក។ ទីពីរ គោរពព្រះគ្រីស្តជាព្រះបន្ទូលនៃព្រះជាម្ចាស់។ ទីបីគោរពព្រះគ្រីស្តជាប្រភពនៃជីវិត និងទីបួន ព្រះយេស៊ូប្រទានព្រះកាយ និងព្រះលោហិតព្រះអង្គទុកជាអាហារ។

កញ្ញា លាភ សម្ប័ទ កាតារីណា បានមានប្រសាសន៍ថា នាងហាក់បីដូចជាបានឃើញពន្លឺព្រះគ្រីស្តដោយនាងបានសម្រេចចិត្តយកព្រះគ្រីស្តជាទីពឹង យកព្រះបន្ទូលជាទីពឹង និងព្រះសហគមន៍ជាទីពឹង។

កញ្ញា សម្ប័ទបានបន្តទៀតថានាងមានអារម្មណ៍ឈប់ភ័យខ្លាច។









# ព្រះសហគមន៍ផ្លូវត្រីប្រារព្ធពីធីរំលឹកដល់មរណសាក្សី ត្រឿង ប៊ូរយៀប

ពិធីរំលឹកដល់មរណសាក្សី ត្រឿង ប៊ូរយៀប ត្រូវបានប្រារព្ធធ្វើឡើងនៅព្រះសហគមន៍ផ្លូវត្រីដែលស្ថិតនៅស្រុកល្វាឯម ខេត្តកណ្តាល កាលពីថ្ងៃទី១២ មីនាកន្លងទៅនេះ។

មានអ្នកចូលរួមជាច្រើននាក់បានមូលផ្តុំគ្នាដើម្បីទទួលស្វាគមន៍រូបសំណាក់លោក យៀបនៅថ្ងៃនោះ។

លោក ប៊ូយៀប ត្រូវបានគេគោរព និងចាត់ទុកជាមរណសាក្សីនៅប្រទេសវៀតណាម។ តាមលោក ឡេ យ៉ាំងចាកជាប្រធានសង្ឃហៈនៅព្រះសហគមន៍ចំប៉ា មានប្រសាសន៍ថា លោកមូលហេតុដែលគ្រីស្តបរិស័ទនៅប្រទេសកម្ពុជារំលឹកដល់លោកប៊ូយៀប ព្រោះថា លោកជាមរណសាក្សីម្នាក់ដែលមានភាពល្បីល្បាញនៅប្រទេសវៀតណាមតែលោកធ្លាប់រស់នៅនិងបម្រើព្រះសហគមន៍នៅប្រទេសកម្ពុជាអស់រយៈពេលជាច្រើនឆ្នាំដែរ។ លោកបន្តទៀតថា លោកបូជាចារ្យ ប៊ូយៀបទទួលការស្រលាញ់និងគោរពពីសំណាក់គ្រីស្តបរិស័ទនៅវៀតណាម ហើយមនុស្សជាច្រើននាក់បានអធិដ្ឋានបានសម្រេចតាមរយៈលោក។

លោកបូជាចារ្យហ្វ្រង់ស័រ ត្រឿងប៊ូរយៀបកើតថ្ងៃទី១ មករា ឆ្នាំ១៨៩៧ នៅប្រទេសវៀតណាម។ នៅអាយុ៧ឆ្នាំ ក្រុមគ្រួសាររបស់លោកបានមករស់ប្រទេសកម្ពុជាដោយធ្វើជាជាងឈើនៅខេត្តបាត់ដំបង។ លោកទទួលអគ្គសញ្ញាតែងតាំងអាបូជាចារ្យនៅឆ្នាំ១៩២៤។ ចាប់ពីឆ្នាំ១៩២៤ដល់ឆ្នាំ១៩២៧ លោកទទួលខុសត្រូវព្រះសហគមន៍ផ្លូវត្រី។

# Fr. Truong Buu Diep, martyred priest in Vietname

"I live among my flock and I will die among them. I will not go anywhere," said Father François Xavier Truong Buu Diep, who was killed by the Communists on 12 March 1946 in Tac Say, southern Vietnam, almost 2,000 kilometres from the capital of Hanoi, along with 30 other Catholics.

Father Diep was born in 1897 and was ordained a priest in 1924, after completing his studies at the Phnom Penh Major Seminary in Cambodia. During his ministry in Vietnam, the country was torn apart by war. In that period the Việt Minh came down harshly on the country's Catholic community.

The most remarkable story about Fr. Diep concerns his burial place. According to the faithful, when his tomb was built, the owner of the construction company that did the work said that Father Diep appeared to him and gave him the money directly into his hands.

It seems that Fr. Diep, from heaven, continues to help people everywhere. One example is that of Rose and Ben Hinahon, owners of a shop that sells religious objects and images in San Diego, California. By praying to Father Diep, the Hinahons were able to overcome a deep financial and spiritual crisis.

# បុណ្យទេវទូតជូនដំណឹងដល់ព្រះនាងម៉ារី នៅផ្សារតូច

បុណ្យទេវទូតជូនដំណឹងដល់ព្រះនាងម៉ារីត្រូវបានប្រារព្ធធ្វើឡើងនៅព្រះវិហារផ្សារតូចកាលពីថ្ងៃទី២៦ មីនា កន្លងទៅ នេះ។

ជាមួយគ្នានោះដែរមានបេក្ខជន១៨នាក់បានទទួលធម៌ជឿពីលោកអភិបាលដើម្បីត្រៀមខ្លួនទទួលពិធីបុណ្យជ្រមុជទឹកនៅក្នុងរាត្រីបុណ្យចម្លងខាងមុខនេះ និងពិធីប្រសិទ្ធពរលើរូបសំណាកព្រះនាងម៉ារី។

លោកបូជាចារ្យប្រ៊ុយណូ មានមានប្រសាសន៍ថា ជាធម្មតាបុណ្យទេវទូតជូនដំណឹងដល់ព្រះនាងម៉ារីគេប្រារព្ធធ្វើឡើងនៅថ្ងៃទី២៥ មីនា។

លោកអភិបាល អូលីវីយេបានជួយឲ្យយើងរិះគិតអំពីព្រះនាងម៉ារីទៅនឹងស្ត្រីនាពេលបច្ចុប្បន្ន។ លោកពោលថា ព្រះនាងម៉ារីជាស្ត្រីដែលរស់នៅដោយភ្ជាប់ជាមួយព្រះជាម្ចាស់ និងមានអំណរសប្បាយ។

*"មនុស្សយើងសព្វថ្ងៃមិនសូវចូលចិត្តរង់ចាំទេ។ ប៉ុន្តែព្រះនាងម៉ារីជួយឲ្យយើងឲ្យមានចិត្តអត់ធ្មត់ដោយមានសេចក្ដីសង្ឃឹម"។*

## Feast of St. Joseph and feast of the Annunciation in Phsar Tauch

The Parish of St. Joseph (Phsar Tauch) celebrated the feast of its patron saint last March 19 with a solemn Mass celebrated by the parish priest, Fr. Bruno Cosme, in the chapel. After the Mass, Fr. Bruno led the parishioners in procession to the statue of St. Joseph. He said that St. Joseph, a discrete and humble man, had the task of providing not only for the material needs of the child Jesus and His Mother, Mary, but most of all, of educating Him. The example of St. Joseph should remind us of the importance of unity in a family.

The feast of the Annunciation was also celebrated on March 26. For this special day, Bishop Olivier presided at the Mass. In his homily, he talked about the Holy Virgin Mary, women of all times. She is the Mother of the Church and an example for every Christian. We can identify with her as we follow the different parts of her life and rediscover her deep humanity. She was not only a suffering mother, but also a disciple obedient to the Word of God. She was a wife, sharing with St. Joseph the daily worries of their family, and also a woman who wanted feasts to be beautiful and not lacking the essentials, like at the Cana wedding.

For this solemn occasion, the parish prepared a new place for the statue of the Virgin Mary which used to stand near the statue of St Joseph. The new place was at the entrance of the compound, where everybody could see Her and feel Her welcoming presence. After the Mass, Bishop Olivier, the priests, and all the parishioners, walked in procession to the new place of the statue where it was installed and crowned with flowers.







រូបភាពបុណ្យចម្លង នៅមណ្ឌលសកម្មភាពទន្លេមេគង្គ

រូបភាពបុណ្យចម្លង នៅមណ្ឌលសកម្មភាពក្រុងព្រះសីហនុ



## រូបភាពបុណ្យចម្លង នៅមណ្ឌលសកម្មភាពតាកែវ








## រូបភាពបុណ្យចម្លង នៅមណ្ឌលសកម្មភាពភ្នំពេញខាងជើង











## រូបភាពបុណ្យចម្លង នៅមណ្ឌលសកម្មភាពទន្លេបាសាក់



## រូបភាពបុណ្យចម្លង នៅមណ្ឌលសកម្មភាពកំពត









## រូបភាពរដូវអប់រំពិសេស និងបុណ្យចម្លង នៅមណ្ឌលសកម្មភាពភ្នំពេញខាងត្បូង









# សក្ខីភាពអ្នកទទួលពិធីបុណ្យជ្រមុជទឹកក្នុងឱកាសបុណ្យចម្លង



(អឿន ម៉េងហួរ) បុណ្យចម្លង យើងគួររំលឹកអត្ថន័យ ព្រះយេស៊ូរងទុក្ខលំបាកក្នុងជីវិតប្រចាំថ្ងៃនៅកម្ពុជាបច្ចុប្បន្ន។ យើង ទាំងអស់គ្នាគួរឲ្យមានមោទនភាព ព្រោះមានគ្រីស្តបរិស័ទមានចំនួនកាន់តែច្រើនឡើងៗជារៀងរាល់ឆ្នាំធ្វើ ឲ្យព្រះសហគមន៏នៅកម្ពុជាកាន់តែធំឡើង។

យើងទាំងអស់គ្នាជាគ្រីស្តបរិស័ទមានតួនាទីយ៉ាងសំខាន់ក្នុងចូលរួមធ្វើជាសក្ខីភាពនៅក្នុងសង្គមពីវត្តមានរបស់ព្រះជាម្ចាស់។

នៅឱកាសបុណ្យចម្លង យើងរិះគិតអំពីព្រះយេស៊ូរងទុក្ខលំបាកដោយសុខចិត្តបូជាព្រះជន្មព្រះអង្គលើឈើឆ្កាង។ នៅក្នុងជីវិត រស់នៅប្រចាំថ្ងៃ បងប្អូន គ្រីស្តបរិស័ទទាំងអស់ត្រូវពិចារណាអំពីរបៀបដែលខ្លួនអាចលះបង់ជីវិតផ្ទាល់ខ្លួន។ មានន័យថាយើងត្រូវរិះគិតថាតើខ្លួនអាចលះបង់ពេលវេលានិង ផលប្រយោជន៍ផ្ទាល់ខ្លួន ធ្វើជាប្រយោជន៍ដល់សង្គមជាតិយ៉ាងដូចម្ដេច?។

មានព្រះគម្ពីរមួយឃ្លាដែលខ្ញុំពេញចិត្តគឺ "អ្នកដែលចូល ក្នុងព្រះរាជ្យនៃស្ថានបរមសុខ មិនមែន គ្រាន់តែហៅខ្ញុំថាព្រះអង្គម្ចាស់ៗ! ប៉ុណ្ណោះទេ គឺអ្នកដែលធ្វើតាមព្រះហឫទ័យរបស់ព្រះបិតាខ្ញុំ ដែលគង់នៅស្ថានបរមសុខនោះវិញ"។ គ្រីស្តបរិស័ទគួរតែធ្វើជាគំរូដល់អ្នកឯទៀតក្នុងជីវិតរស់នៅបច្ចុប្បន្នក្នុងសង្គម។ ប្រសិនបើគ្រីស្តបរិស័ទនៅលើពិភពលោកអាចយល់សេចក្តីនេះ ហើយអនុវត្តគ្រប់ៗគ្នា នោះពិភពលោកពិតជានឹងមានការផ្លាស់ប្តូរជាវិជ្ជមានដោយសារព្រះសហគមន៍មិនខានឡើយ។

Easter reminds us the suffering of Jesus in our daily life in the present day. As we are a Catholic, we should feel proud as the number of Catholic is increasing and lead the church growing bigger and bigger from year to years. As a Catholic, we play a very important role to bring God's presence in our society. Easter helps us to think about the way how to share our life.



ខ្ញុំមកពីគ្រួសារដែលជាពុទ្ធបរិស័ទ។ នៅពេលឪពុកម្តាយខ្ញុំលឺថា ខ្ញុំសម្រេចចិត្តស្វែងយល់ពីជំនឿកាតូលិក ពួកគាត់មានការព្រួយបារម្ភជាខ្លាំង។ ពួកគាត់ធ្លាប់និយាយប្រាប់ខ្ញុំថា មានអ្នកដទៃបាននិយាយថា សាសនានេះបានបង្រៀនមនុស្សឲ្យមិនគោរពឪពុកម្តាយ។ ពួកគាត់គិតថា ខ្ញុំភ្លេចជាតិសាសន៍ខ្លួនឯងដោយទទួលយកសាសនាបរទេស។ អ្វីៗទាំងអស់ត្រូវបានលាតត្រដាងឲ្យគាត់យល់បានច្បាស់តាមរយៈការពន្យល់និងទង្វើរបស់ខ្ញុំ។ ខ្ញុំពិតជាពេញចិត្តចំពោះជីវិតជាគ្រីស្តបរិស័ទ។ ចំនុចពីរដែលខ្ញុំមើលឃើញក្នុងជីវិតជាគ្រីស្តបរិស័ទ គឺ ការចេះជួយគ្នាទៅវិញទៅមក និងការអធិដ្ឋាន។ ជាក់ស្តែងយើងបានចំណាយពេលវេលារបស់ខ្លួនដើម្បីលើកទឹកចិត្តនិងសួរសុខទុក្ខអ្នកជម្ងឺ និងអ្នកគ្មានទីពឹង។ ជាងនេះទៅទៀតការអធិដ្ឋានបានធ្វើឲ្យខ្ញុំមានអារម្មណ៍ស្ងប់ និងមានសេចក្តីសង្ឃឹម។

I come from Buddhism family background. My parents seemed not to be very happy when they hear that I would be a Catholic. They said Christianity teach people not to respect parents. They thought that I forget my own religion and receive the foreign one. Everything is revealed through my action and explanation. I do love Catholic faith. Two important things I have found in Catholic life are: prayer and help each other. Prayer make me comfortable and hopeful.

# ពិធីបុណ្យប្រសិទ្ធពរលើព្រេង





ពិធីប្រសិទ្ធពរលើព្រេងបានប្រារព្ធធ្វើឡើងបានធ្វើឡើងនៅព្រះវិហារផ្សារតូចកាលពីថ្ងៃទី២៨ខែមិនាកន្លងទៅនេះ។

លោកអភិបាល លោកបូជាចារ្យដែលកំពុងបម្រើការងារនៅក្នុងប្រទេសកម្ពុជាបានមកជួបជុំដើម្បីប្រសិទ្ធពរលើប្រេង។

នៅក្នុងពិធីនោះដែរលោកអភិបាលបានធ្វើពិធីប្រកាសពាក្យសច្ចារជាថ្មីឡើងវិញរបស់លោកបូជាចារ្យផងដែរ។ ប្រេងដែលត្រូវបានប្រសិទ្ធពររួចអាចយកទៅប្រើប្រាស់បានបីយ៉ាងគឺ ប្រេងសម្រាប់លាបឲ្យអ្នកជម្ងឺ ទីពីរ សម្រាប់លាបឲ្យអ្នករៀបចំខ្លួនទទួលអគ្គសញ្ញាជ្រមុជទឹក ទីបី ប្រេងគ្រីស្មាសម្រាប់លាបឲ្យអ្នកទទួលអគ្គសញ្ញាជ្រមុជទឹក និងទទួលអគ្គសញ្ញាលាបថ្ងាសព្រមទាំងសម្រាប់លាបឲ្យលោកបូជាចារ្យដែលលោកអភិបាលទើបនឹងតែងតាំងឡើង។

## Cambodian Churches Celebrate the Blessing Chrism at Phsar Tauch

Hundreds of people including priests, sisters and brothers who are serving in Cambodia participated at the Chrism Mass at Phsar Toick last March 28. All the priests renewed their priestly promises and showed unity among themselves and with their Bishops.

Chrism is used in the administration of the Sacraments of Baptism, Confirmation, and Holy Orders, in the consecration of churches, chalices, patens, altars, and altar-stones, and in the solemn blessing of bells and baptismal water. The head of the newly-baptized is anointed with chrism, the forehead of the person confirmed, the head and hands of a bishop at his consecration, and the hands of a priest at his ordination. During the celebration, there was also the blessing of oils for the the sick and for the catechumens.

One of those present, Mr. Thon Socheat said, “I am very excited to see all priests present, even some of them I don’t know. I feel that this is one of the greatest moments in the church as we come together as one family. Obviously, priests are very busy with their so many activities, but I really appreciate them that they could come here today. The church needs more priests. As we can see clearly in Kompong Thom, there is only one priest who runs 7 communities.”

# សាលាអប់រំគ្រីស្តបរិស័ទកំពុងបោះជំហានទៅមុខ

និស្សិត៤៥នាក់នៃសាលាអប់រំគ្រីស្តបរិស័ទបានបញ្ចប់ការសិក្សាឆមាសទីមួយកន្លងទៅថ្មីៗនេះ។ លទ្ធផលបណ្តោះអាសន្ននៃឆមាសទីមួយនេះបានបង្ហាញថា មាននិស្សិតប្រហែលជា៦៥%ទៅ៧០%បានប្រឡងជាប់ដោយជោគជ័យ។

The first semester is over last month and the second one has come at the School for the Baptized. According to temporary results, 65-70 percent of the 45 students have successfully passed the first semester exam.



លោកផុនសុផុលជានាយកសាលានេះមានប្រសាសន៍ថា ទោះបីជាយ៉ាងណាលោកនៅតែមានមោទនភាពចំពោះលទ្ធផលនេះ។ លោកពោលថា ចំនួននិស្សិសនៅដដែលហើយបរិយាកាសក្នុងថ្នាក់មានសភាពស្ងប់ស្ងាត់តែនិស្សិតប្រកបដោយមានភាពប្រកួតប្រជែង។ លោកបន្តទៀតថា លោកសាស្ត្រាចារ្យក៏មានការទទួលខុសត្រូវខ្ពស់ដោយបានរៀបចំមាតិការយ៉ាងត្រឹមត្រូវហើយពន្យល់សេចក្តីសរុបនៃមេរៀននីមួយៗផង។

Mr. Phon Sophal (Executive Director), said, “I am proud of the school. I’ve seen that most of the students tried very hard and were competitive. On the other hand, for those who failed or got lower marks, we still encourage them to walk ahead with the others. Obviously, professors are, for their part, trying their best to organize the programme and teach their respective subjects better.



ខ្ញុំពេញចិត្តចំពោះកម្មវិធីសិក្សានៅសាលានេះព្រោះវាជាឱកាសល្អដែលធ្វើឲ្យខ្ញុំយល់ដឹងច្រើនអំពីប្រវត្តិសាស្ត្រព្រះសហគមន៍។ ជាងនេះទៅទៀតខ្ញុំយល់ដឹងអំពីតួនាទីរបស់គ្រីស្តបរិស័ទក្នុងការអនុវត្តសីលធម៌គ្រីស្តបរិស័ទនិងសីលធម៌តាមបែបសង្គមជាក់ស្តែង។ អ្វីដែលជាការលំបាករបស់ខ្ញុំគឺពុំមានពេលគ្រប់គ្រាន់ដើម្បីធ្វើកិច្ចការដែលលោកសាស្ត្រាចារ្យដាក់ឲ្យធ្វើនៅផ្ទះព្រោះខ្ញុំជួនកាលរវល់ជាមួយការងារ។ (ថុង ថន)

Thong Than, a student, said: “This is one of the most important occasions which allow me to understand more about the history of the churches. Moreover, it makes me be more aware of the Christian role to practice morality in society. I love all the subjects, but the obstacle is that I have less time to do our home work. Therefore, I got less marks.”



ខ្ញុំយល់ឃើញថាសាលានេះពិតជាមានសារៈសំខាន់ណាស់ព្រោះធ្វើបានធ្វើឲ្យខ្ញុំនឹងមិត្តភក្តិដទៃទៀតទទួលបានចំណេះដឹងទំលំទូលាយជាងមុន។ ចំណេះដឹងទាំងប៉ុន្មានដែលខ្ញុំទទួលបានក្នុងសាលានេះបានជួយឲ្យខ្ញុំអាចរស់នៅនឹងចែកចាយជាមួយអ្នកដទៃដោយត្រឹមត្រូវ ជាពិសេសសម្រាប់ការអប់រំជំនឿ។ (សុធី)

Chhum Sothy, another student said, “This school is very important for us to deepen our knowledge and faith. This school helps me to live and share my life in an appropriate way.

# សកម្មភាពការិយាល័យយុវជន និងកុមារភូមិភាគភ្នំពេញរយៈពេលបីខែ គិតពីខែមករា ដល់ខែមីនា ឆ្នាំ២០១២

## Pastoral Youth Office Activities Three month reports

## From January to March 2012

១.សកម្មភាពយុវជន

ដោយការិយាល័យយុវជនក្នុងឆ្នាំ ២០១១-២០១២ នេះបានផ្ដោតទៅលើប្រធានបទ នៅជាមួយព្រះយេស៊ូ ដែលក្នុងនោះការិយាល័យុវជនតែងតែធ្វើសិក្ខាសាលាចំនួន៣ដង ក្នុងមណ្ឌលសកម្មភាពនិមួយៗ ក្នុងភូមិភាគភ្នំពេញ។

1. Youth Activities

Pastoral Youth Office, in 2012, focus on the topic: "BE WITH JESUS". So there will be three workshop organized in each pastoral center.

សិក្ខាសាលាទី១ ដែលយើងបានធ្វើក្រោមប្រធានបទ ព្រះយេស៊ូប្រសូតជាមនុស្ស យើងបានធ្វើចំនួន៤ មណ្ឌលសកម្មភាពគឺ

First workshop: "Jesus becomes Human Being."



១៤-១៥ មករា ធ្វើនៅមណ្ឌល សកម្មភាពតាកែវ,
Takeo Pastoral Centre January 14-15,



២១-២២ មករា ធ្វើនៅមណ្ឌលសកម្មភាពកំពត,
Kompot January 21-22,



២៨-២៩ មករា ធ្វើនៅមណ្ឌលសកម្មភាពកំពង់សោម,
Sihanukville January 28-29,



៣-៤ មិនា នៅព្រះសហគមន៍អរិយក្សត្រ។
Aryaksat March3-4

សិក្ខាសាលាទី២ ក្រោមប្រធានបទ ព្រះយេស៊ូសម្តែងឋានៈព្រះអង្គ។




ប្រជុំប្រធានអនុប្រធានយុវជនភូមិភាគភ្នំពេញនៅថ្ងៃទី ៧-៨ ខែមីនា ក្នុងព្រះ សហគមន៍បឹងទំពុន។ ការប្រជុំនេះគឺ ដើម្បីរិះគិតអំពីរបៀបនៃការណែនាំសិក្ខា សាលាទី៣ និងមានឱកាសពិភាក្សាអំពីសន្និបាតយុវជនភូមិភាគភ្នំពេញ។





២.សកម្មភាពកុមារ

សិក្ខាសាលាទី២ដើម្បីអបរំមេក្រុមកាយរិទ្ធបន្ថែម ដែលបានប្រព្រឹត្តទៅនៅ ថ្ងៃទី៩-១១ ខែមីនា ឆ្នាំ២០១២។ ចំនួនមេកាយរិទ្ធដែលបានចូលរួមគឺមានចំនួន សរុបទាំងអស់ ១៧៦នាក់។




# សម្រង់អត្ថាធិប្បាយព្រះបន្ទូល របស់លោកអភិបាល អូលីវីយេ ក្នុងពិធីសម្ពោធបដិមារព្រះនាងម៉ារី នៅព្រះវិហារសន្ត យ៉ូសែប ផ្សារតូច ភ្នំពេញ ២៦/០៣/២០១២ លូកា ១, ២៦-៣៨

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះជាឱកាសមួយដ៏ល្អដើម្បីគិតអំពីព្រះនាងម៉ារី ពិតមែនព្រះនាងក៏ជានិមិត្តរូបសម្រាប់ស្ត្រីនៃបច្ចុប្បន្ននេះដែរ មិនមែនតែជាព្រះជាមាតាព្រះយេស៊ូកាល ២០០០ ឆ្នាំមុននោះទេ។ សម្ដេចប៉ាបពីមុន ធ្លាប់មានប្រសាសន៍ថា ព្រះនាងម៉ារីដូចជាកញ្ចក់មួយដើម្បីឲ្យទាំងស្ត្រីទាំងបុរស ឆ្លុះមើលឃើញពីជីវិតផ្ទាល់របស់ខ្លួន និងជួយឲ្យបានរីកចម្រើននៅក្នុងលក្ខណៈជាមនុស្ស។ ប៉ុន្តែជួនកាលយើងទុកព្រះនាងម៉ារីជាស្ត្រីម្នាក់ពិសេសអស្ចារ្យ ដោយសារព្រះនាងជាព្រះមាតាព្រះជាម្ចាស់ ហើយគិតថាយើងមិនអាចធ្វើដូចព្រះនាងម៉ារីបានទេ។ ប៉ុន្តែថ្ងៃនេះខ្ញុំចង់ឲ្យបងប្អូនរកឃើញពីក្នុងអត្ថបទគម្ពីរដំណឹងល្អ នូវរបៀបដែលព្រះនាងម៉ារីជួយយើង ដើម្បីឲ្យយើងយល់កាន់តែច្បាស់អំពីឋានៈរបស់យើងជាមនុស្ស និងត្រូវធ្វើយ៉ាងដូចម្ដេចដើម្បីឲ្យយើងទៅជាមនុស្សពេញលក្ខណៈដោយសារព្រះនាងម៉ារី?។ តាមពិតព្រះនាងម៉ារីជួយយើងឲ្យទៅជាបុរសជាស្ត្រីពេញលក្ខណៈ ដោយពឹងផ្អែកទៅលើព្រះជាម្ចាស់ទាំងស្រុង។

ទីមួយ ព្រះនាងម៉ារី ជាយុវនារី ជាសាវ័ករបស់ព្រះជាម្ចាស់ ៖ អត្ថបទដែលយើងបានស្ដាប់អំបាញ់មិញ យើងឃើញថាព្រះនាងជាយុវនារីម្នាក់ដែលមានសមត្ថភាព ដើម្បីទទួលដំណឹងល្អមួយដ៏អស្ចារ្យមែនទែន ដែលនាំឲ្យយើងយល់ថាព្រះនាងចេះគិត ចេះពិចារណា ចេះស្ដាប់ព្រះបន្ទូល ចេះវិនិច្ឆ័យត្រឹមត្រូវ និងចេះទទួលដំណឹងមួយពិសេសនៅក្នុងជំនឿរបស់ព្រះនាង។ នេះណែនាំឲ្យយើង ឲ្យយុវជនយុវនារីទាំងអស់ទូទាំងពិភពលោក យកព្រះនាងម៉ារីជាគំរូរបស់ខ្លួន។ សព្វថ្ងៃ ជួនកាលយើងនិយាយថា យុវជនគេឥតចេះស្ដាប់ គេធ្វើតាមចិត្ត គេមិនចេះវិនិច្ឆ័យស្អីសោះ ប៉ុន្តែតាមពិត ពេលយើងឃើញព្រះនាងម៉ារី ដែលជាយុវនារីម្នាក់ មានអាយុតែ ១៥-១៦ ឆ្នាំ ព្រះនាងចេះស្ដាប់ ចេះវិនិច្ឆ័យ ប្រព្រឹត្តតាមព្រះហឫទ័យព្រះជាម្ចាស់ និងផ្ញើចិត្តសង្ឃឹមលើព្រះជាម្ចាស់ទៀតផង។ ដូច្នេះនេះក៏ណែនាំឲ្យយុវជនយុវនារីយើងទាំងអស់យកចិត្តទុកដាក់សាជាថ្មីដែរ ដើម្បីស្ដាប់ ដើម្បីវិនិច្ឆ័យត្រឹមត្រូវ ដើម្បីប្រព្រឹត្តតាមព្រះ បន្ទូលរបស់ព្រះជាម្ចាស់ និងដើម្បីមានសេចក្ដីសង្ឃឹមលើវត្តមានរបស់ព្រះអង្គនៅក្នុងសង្គមដែលជួនកាលណែនាំឲ្យយើងភ្លេចព្រះជាម្ចាស់។

ទីពីរព្រះនាងម៉ារីជាស្ត្រីម្នាក់ ដែលធ្វើដំណើរ៖ ពេលព្រះនាងម៉ារីបានទទួលដំណឹង គាត់បានចេញ ដំណើរទៅជួបនាងអេ-លីសាបែតភ្លាម។ តាមពិតព្រះនាងម៉ារីបានយល់ច្បាស់ថា នាងអេលីសាបែត កំពុងរង់ចាំការលើកទឹកចិត្ត រង់ចាំសេចក្ដីមួយដូច្នេះព្រះនាងធ្វើដំណើរចេញទៅលើកទឹកចិត្តគាត់ បង្កើតទំនាក់ទំនងឲ្យគាត់មានអំណរសប្បាយថែមរួមជាមួយព្រះនាងដែរ។ សព្វថ្ងៃ នៅក្នុងពិភពលោកទាំងមូល យើងចូលចិត្តធ្វើដំណើរដែល បង្កើតជាទំនាក់ទំនងថ្មី ណែនាំឲ្យយើងបើកចិត្តគំនិត។ ខ្ញុំគិតថាព្រះនាងម៉ារីនឹងជួយឲ្យយើងធ្វើដំណើរតាមលក្ខណៈល្អ មានសេចក្ដីសុខ សេចក្ដីសង្ឃឹម ឲ្យយើងបង្កើតទំនាក់ទំនងយ៉ាងល្អជាមួយបងប្អូនឯទៀតៗដែរ ជាពិសេសយើង ក៏នឹកឃើញដល់បងប្អូនខ្មែរយើងជាច្រើន ដែលធ្វើដំណើរទៅធ្វើការនៅថៃ ទៅកូរ៉េ ទៅម៉ាឡេ។ សូមឲ្យយើងយកព្រះនាងម៉ារីជាគំរូ កុំឲ្យយើងធ្វើដំណើរដោយឥតគិតពីគោលដៅ ប៉ុន្តែឲ្យយើងចែកអ្វីដែលយើងមាននៅក្នុងជីវិតរបស់យើងដែរ។

ទីបីព្រះនាងម៉ារីជាស្ត្រីដែលមានផ្ទៃពោះ៖ ពេលព្រះនាងម៉ារីបានទទួលដំណឹងថាមានផ្ទៃពោះ ព្រះនាងបានកោតសរសើរព្រះជាម្ចាស់ បង្ហាញពីអំណរសប្បាយដែលព្រះនាងបានទទួល។ ព្រះនាងម៉ារី ទៅជាមាតារបស់ព្រះ យេស៊ូ ជាមាតារបស់ព្រះជាម្ចាស់ពិតមែន ជីវិតដែលព្រះនាងទទួលនៅក្នុងផ្ទៃ ជាជីវិតសម្រាប់ពិភពលោកទាំងមូល។ ព្រះនាងចែកអំណរសប្បាយនេះជាមួយនាងអេលីសាបែត និងក៏ចែកជាមួយយើងសព្វថ្ងៃដែរ។ ខ្ញុំគិតថានេះជាការសំខាន់សម្រាប់ស្ត្រីទាំងអស់ដែលមានផ្ទៃពោះ ត្រូវមានអំណរសប្បាយនៅពេលទទួលដំណឹងថានឹងទៅជាម្ដាយនៅថ្ងៃអនាគត។ សព្វថ្ងៃពេលយើងមានកូនទីមួយយើងសប្បាយចិត្ត ពេលមានកូនទីពីរយើងសប្បាយល្មម ប៉ុន្តែពេលមានកូនទីបីនោះយើងចាប់ផ្ដើមគិតច្រើន ហើយឥឡូវនេះក៏កាន់តែប្រែប្រួល

ថែមទៀត គឺពេលមានកូនទីពីរ យើងនិយាយថាមានកូនពិបាកណាស់។

ទីបួនព្រះនាងម៉ារីជានិមិត្តរូបនៃស្ត្រីទាំងអស់ដែលគេសង្កត់សង្កិន និងដែលត្រូវភៀសខ្លួន៖ ព្រះនាងម៉ារីមិនអាចសម្រាលព្រះឱរសនៅភូមិណាសារ៉ែតបានទេ ព្រោះជិតដល់ថ្ងៃសម្រាលព្រះនាងត្រូវចេញដំណើរទៅភូមិបេថ្លេហិម ដែលឥតមានសុវត្ថិភាព ឥតមានមណ្ឌលសុខភាព ឥតមានក្រុមគ្រួសារដើម្បីលើកទឹកចិត្ត និងក្រោយពេលព្រះនាងសម្រាលព្រះឱរសហើយភ្លាមព្រះនាងម៉ារីរួមជាមួយលោកយ៉ូសែប ត្រូវចេញដំណើរទៅប្រទេសអេស៊ីបទៀត ដោយសារស្តេចហេរ៉ូដតាមសម្លាប់ទារកទាំងអស់។ ដូច្នេះព្រះនាងជាជនភៀសខ្លួន និងជានិមិត្តរូបនៃស្ត្រីទាំងអស់នៅក្នុងពិភពលោកសព្វថ្ងៃដែលត្រូវភៀសខ្លួនចេញពីផ្ទះ ពីក្រុមគ្រួសារដោយសារសង្គ្រាម ដោយសារ រកការងារធ្វើ ដើម្បីចិញ្ចឹមកូន...។

ទីប្រាំព្រះនាងម៉ារីជាស្ត្រីដែលបានរៀបការ ៖ ជានិមិត្តរូបនៃប្រពន្ធទាំងឡាយ។ នៅទីក្រុងយេរូសាឡឹម ពេលបាត់ព្រះកុមារយេស៊ូ យើងឃើញព្រះនាងម៉ារីនិងលោកយ៉ូសែប រួមគ្នាខិតខំស្វែងរកកូន។ នេះយើងយល់ភ្លាមថា ព្រះនាងម៉ារី និងលោកយ៉ូសែប ដូចជាសហការគ្នា ជួយគ្នាដើម្បីថែរក្សាក្រុមគ្រួសារ នេះជានិមិត្តរូបនៃប្តីប្រពន្ធទាំងអស់ ដែលត្រូវតែយកចិត្តទុកដាក់ ជួយគ្នាទៅវិញទៅមក និងត្រូវយកចិត្តទុកដាក់ចំពោះកូនរបស់ខ្លួនផ្ទាល់ដែរ។

ទីប្រាំមួយព្រះនាងម៉ារី ជាស្ត្រីដែលចូលចិត្តជប់លៀង និងចូលចិត្តសប្បាយដែរ ៖ យើងនឹកឃើញដល់មង្គលការនៅភូមិកាណា។ ពេលព្រះនាងម៉ារីឃើញថាអស់ស្រាហើយ ព្រះនាងផ្តល់ដំណឹងទៅព្រះយេស៊ូភ្លាម ឲ្យជួយគេ។ ពេលព្រះនាងម៉ារីធ្វើដូចនេះ ណែនាំឲ្យគេគ្រប់គ្នាមានអំណរសប្បាយតទៅទៀត។ យើងយល់ថា អំណរសប្បាយជាពេលវេលាមួយដ៏សំខាន់នៅក្នុងជីវិតរបស់យើង សម័យបច្ចុប្បន្នយើងមានពិធីជប់លៀងជាច្រើនមានរបៀបសប្បាយច្រើនយ៉ាង ដូចជាគ្រឿងញៀន ស្រា រឿងភេទ ណែនាំឲ្យយុវជនយុវនារីគេចង់សប្បាយ ឲ្យយើងវង្វេង ចុងក្រោយបំផុតបំផ្លាញជីវិតនិងបំផ្លាញអនាគត។

ទីប្រាំពីរព្រះនាងម៉ារី ជាម្តាយដែលទទួលទុក្ខលំបាកខ្លាំងណាស់៖ យើងនឹកដល់ព្រះនាងម៉ារីនៅក្បែរឈើឆ្កាងព្រះយេស៊ូ។ ពេលនោះនៅសល់តែម្តាយដែលនៅក្បែរកូន នៅសល់តែម្តាយដែលកំពុងសម្លឹងមើលកូនដែលបានសោយទិវង្គត កូនដែលគេចាប់យកមកសម្លាប់ កូនដែលឥតបានធ្វើអីខុសសោះ។ ខ្ញុំគិតថា ព្រះនាងម៉ារីជានិមិត្តរូបឲ្យស្ត្រីទាំងអស់មានសេចក្តីក្លាហានឡើង ដើម្បីឲ្យជីវិតទទួលបានជោគជ័យគ្រប់ពេលវេលា។ ជានិមិត្តរូបនៃស្ត្រីទាំងអស់ដែលខិតខំការពារកូន រក្សាកូនដែលជួបបញ្ហាយ៉ាងច្រើននាពេលបច្ចុប្បន្ននេះ ព្រះនាងម៉ារីជួយឲ្យព្រះជាម្ចាស់បង្ហាញព្រះហឫទ័យប្រណីសន្តោសរបស់ព្រះអង្គដល់មនុស្សទាំងអស់។ សព្វថ្ងៃ នៅក្នុងសង្គមរបស់យើង មានកូនក្មេងយ៉ាងច្រើនដែលឥតមានសុភមង្គល ឥតមានសិទ្ធិត្រឹមត្រូវ ឥតមានអនាគតភ្លឺស្វាងសោះ និងម្តាយខិតខំលើកទឹកចិត្ត ខិតខំជំរុញកូនរបស់ខ្លួន។

ទីប្រាំបីព្រះនាងម៉ារីជាស្ត្រី ដែលអធិដ្ឋាន និងទន្ទឹងរង់ចាំព្រះវិញ្ញាណដ៏វិសុទ្ធ នៅក្នុងសេចក្តីសង្ឃឹម ៖ ពេល នេះ យើងនឹកឃើញដល់ព្រះនាងម៉ារីដែលនៅជាមួយក្រុមគ្រីស្តទូតកំពុងរង់ចាំព្រះវិញ្ញាណដ៏វិសុទ្ធយាងមក។ ព្រះវិញ្ញាណដ៏វិសុទ្ធជាសេចក្តីសង្ឃឹមរបស់ព្រះនាងម៉ារី ជាសេចក្តីសង្ឃឹមរបស់ព្រះសហគមន៍ទាំងមូល ហើយគេកំពុងទន្ទឹងរង់ចាំ។ សព្វថ្ងៃនៅក្នុងសង្គមរបស់យើង យើងមិនចូលចិត្តរង់ចាំអីទេ យើងធ្វើអីដោយភ្លាមៗ យើងចង់ញ៉ាំកាហ្វេ យើងដាក់ម្សៅកាហ្វេរួចហើយយើងចាក់ទឹកក្តៅយើងបានកាហ្វេភ្លាម។ សព្វថ្ងៃយើងលែងរង់ចាំសំបុត្រមកពីឆ្ងាយទៀតហើយ យើងផ្ញើអ៊ីម៉ែលភ្លែតដល់ភ្លាម យើងលែងមានចិត្តអត់ធ្មត់។ ប៉ុន្តែសូមមើលព្រះនាងម៉ារីដែលអង្គុយចាំឲ្យព្រះវិញ្ញាណដ៏វិសុទ្ធយាងមកនៅក្នុងសេចក្តីសង្ឃឹម។ នេះខ្ញុំគិតថាជួយយើងដែរ ឲ្យយើងចេះទន្ទឹងរង់ចាំអ្វីមួយសម្រាប់ជីវិតយើងឲ្យយើងចាំបន្តិចម្តងៗ ឲ្យយើងខំពីការងារតូចតាចដើម្បីមានការងារធំ កុំឲ្យចង់បានភ្លាមៗ។ ព្រះ នាងម៉ារីជាគំរូពិសេស ដើម្បីណែនាំឲ្យយើងមានចិត្តអត់ធ្មត់ ឲ្យយើងទន្ទឹងរង់ចាំដោយចិត្តតស៊ូនៅក្នុងសេចក្តីសង្ឃឹមយ៉ាងពិតប្រាកដ។

ហេតុនេះហើយ ដោយរួមជាមួយព្រះនាងម៉ារីដែលជាមាតាដែលជាបងស្រី សូមឲ្យយើងខិតខំយកចិត្តទុកដាក់ទទួលស្វាគមន៍ ទទួលដំណឹងល្អពីព្រះយេស៊ូដែលមានព្រះជន្មរស់ឡើងវិញ។ សូមឲ្យយើងខិតខំចែកជាមួយបងប្អូនឯងទៀតៗនូវដំណឹងល្អ ដើម្បីឲ្យពិភពលោកទាំងមូលមានសេចក្តីសង្ឃឹម ពិភពលោកដែលកសាងសង្គម ពិភពលោកដែលប្រកបដោយយុត្តិធម៌ និងសេចក្តីស្រឡាញ់ពិតមែន។ អាម៉ែន។

# សិក្ខាសាលាអ្នកណែនាំក្រុមកាយឫទ្ធិ

ប្រធានក្រុមកាយឫទ្ធិចំនួន១៧៦នាក់ដែលមកពីបណ្ដាព្រះសហគមន៍ក្នុងភូមិភាគភ្នំពេញបានចូលរួមសិក្ខាសាលាមួយដែលរៀបចំឡើងដោយការិយាល័យយុវជននិងកុមារនៅក្រុងព្រះសីហនុកាលពីថ្ងៃទី៩-១១ខែកុម្ភៈកន្លងទៅនេះ។

លោក អន វិចិត្រជាអ្នកសម្របសម្រួលកម្មវិធីនេះមានប្រសាសន៍ថាសិក្ខាសាលានេះផ្ដោតទៅលើចំនុចបួនសំខាន់ៗ គឺ ណែនាំឲ្យចេះប្រើប្រាស់សៀវភៅដែលបានរៀបចំឡើងដោយការិយាល័យ ចែកឯកសណ្ឋាន ផ្ដល់ករុកោសល្យ និងចែកចាយបទពិសោធន៍។

លោកថៃ បញ្ញា ជាប្រធានក្រុមកាយឫទ្ធិព្រះសហគមន៍ផ្សារតូចមានប្រសាសន៍សិក្ខាសាលានេះពិតជាមានសារៈប្រយោជន៍សម្រាប់ប្រធានកាយឫទ្ធិដែលមានការសិក្សាតិចតួចព្រោះវាបានផ្ដល់មូលដ្ឋាគ្រឹះករុកោសល្យ។ លោកបានបន្តទៀតថាកម្មវិធីនេះបានជួយឲ្យអ្នកចូលរួមមានភាពក្លាហាន បង្កើនមិត្តភាពរវាងគ្នានឹងគ្នា និងមានការលះបង់ដោយមានទំនួលខុសត្រូវចំពោះអ្វីដែលគេធ្វើ។

ក្រុមកាយឫទ្ធិត្រូវបានបង្កើតឡើងនៅគ្រប់កន្លែងតាមព្រះសហគមន៍នីមួយៗនៅទូទាំងភូមិភាគភ្នំពេញដោយមានគោលបំណងដើម្បីផ្ដល់ឱកាសឲ្យកុមារទាំងឡាយយល់ដឹងអំពីអនាម័យសង្គមរស់នៅជាមួយគ្រួសារមិត្តភក្តិ និងឲ្យគេក្លាយទៅជាមនុស្សមានប្រយោជន៍នៅក្នុងសង្គម។

## Scout Leaders Come For Second Workshop

A total of 176 scout leaders participated in the the second workshop organized by the Youth-Children Office on March 9-11 at Sihanoukville.

Mr. Orn Vichet, the coordinator, said that the objective of this workshop was to give guidelines on how to use the books, share experiences and to distribute uniforms.

Mr. Thai Panha, a scout leader at Phsar Toick, said: "This is a good workshop and necessary for those who have a little education; it provides basic knowledge. After the workshop, I found that each participant had become more brave, friendly, and responsible".



## Activities of Bishop Olivier Schmitthaeusler, MEP
## Apostolic Vicar of Phnom Penh,
## April 2012

ថ្ងៃទី៥ មេសា ៖ ព្រឹក ៖ ប្រជុំក្រុមប្រឹក្សាលោកអភិបាល
៖ ល្ងាច ៖ ប្រារព្ធបុណ្យព្រះយេស៊ូជប់លៀងចុងក្រោយ និងអធិដ្ឋានពេញមួយយប់នៅព្រះសហគមន៍ចំប៉ា សម្រាប់ការត្រាស់ហៅ

ថ្ងៃទី ៦ មេសា ៖ ប្រារព្ធបុណ្យព្រះយេស៊ូរងទុក្ខលំបាក នៅព្រះសហគមន៍បឹងទំពុន

ថ្ងៃទី៧ មេសា ៖ អភិបូជាបុណ្យព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ (បុណ្យចម្លង) និង ធ្វើអគ្គសញ្ញាជ្រមុជទឹក នៅព្រះវិហារសន្តយ៉ូសែប ភ្នំពេញ

ថ្ងៃទី ៨ មេសា ៖ ព្រឹក ៖ អភិបូជាបុណ្យព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ (បុណ្យចម្លង) នៅព្រះ-សហគមន៍ស្អាង
៖ ល្ងាច ៖ អភិបូជាបុណ្យព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ (បុណ្យចម្លង) នៅព្រះសហគមន៍ចំការទៀង (តាកែវ)

ថ្ងៃទី៩ មេសា ៖ អធិបតីក្នុងពិធីប្រកួតកីឡានៅវិទ្យាល័យសន្តហ្វ្រង់ស្វ័រ

ថ្ងៃទី១០ មេសា ៖ ប្រារព្ធពិធីបុណ្យចូលឆ្នាំខ្មែរប្រពៃណីជាតិនៅវិទ្យាស្ថានសន្តប៉ូល

ថ្ងៃទី១៣ មេសា ៖ អភិបូជាបុណ្យចូលឆ្នាំខ្មែរប្រពៃណីជាតិនៅព្រះវិហារសន្តយ៉ូសែបភ្នំពេញ
៖ ប្រារព្ធពិធីបុណ្យចូលឆ្នាំខ្មែរប្រពៃណីជាតិ នៅមណ្ឌល ភូមិសុខសាន្ត

ថ្ងៃទី១៥ មេសា ៖ អភិបូជាបុណ្យចូលឆ្នាំខ្មែរប្រពៃណីជាតិនៅតាកែវ
៖ ពេលរសៀល ជួបជាមួយអតីតសិស្សវិទ្យាល័យសន្ត ហ្វ្រង់ស្វ័រ

ថ្ងៃទី១៧ ដល់២១ មេសា ៖ អវត្តមាន៖ ដើម្បីពិនិត្យសុខភាព

ថ្ងៃទី២២ មេសា ៖ អភិបូជានៅព្រះសហគមន៍គងនយ

ថ្ងៃទី២៤ មេសា ៖ សំណាក់ធម៌លោកបូជាចារ្យ
៖ អភិបូជា និង ធ្វើបាឋកថា នៅទេវវិទ្យាល័យ កម្ពុជា

ថ្ងៃទី២៥ មេសា ៖ អភិបូជា ជាមួយក្រុម ពីមេ (PIME)

ថ្ងៃទី26 មេសា ៖ ប្រជុំក្រុមប្រឹក្សា ព្រះសហគមន៍

ថ្ងៃទី២៧ មេសា ៖ ប្រជុំប្រចាំខែ ជាមួយគណៈកម្មការព្រះសហគមន៍ មណ្ឌល សកម្មភាពទន្លេមេគង្គ និង ទន្លេបាសាក់ នៅព្រះសហគមន៍ចំប៉ា

ថ្ងៃទី២៨ មេសា ៖ បង្រៀននៅសាលាអប់រំគ្រីស្តបរិស័ទ

ថ្ងៃទី២៨ - ២៩ មេសា ៖ អធិដ្ឋាន អភិបូជាទិវា ការត្រាស់ហៅ និងធ្វើបាឋកថា នៅព្រះសហគមន៍ព្រះកុមារយេស៊ូ បឹងទំពុន ។

April 1st : Recollection and Palm Mass at Choumkiri
April 2nd : Meeting with Teachers of St Francis High School
April 5th : AM : Episcopal Council
: PM : Mass of the Last Supper + Night Prayer for Vocations at Champa
April 6th : Passion at Boeung Toumpun
April 7th : Easter vigil + Baptisms at St Joseph
April 8th : AM : Easter Mass at Saang
: PM : Easter Mass at Takeo
April 9th : Sports Competition at st Francis High School
April 10th : Khmer New Year at st Paul Institute
April 13rd : Khmer New Year Mass at st Joseph
:Khmer New Year Celebration at Peace Village
April 15th : Khmer New Year Mass at Takeo
: PM : at 3pm meeting with Alumni Students of St Francis High School.
April 17th-21th : Absent for health check-up
April 22nd : Mass at Kong Noye Parish
April 24th : Retreat for the priests
: Mass + Conference at the Major Seminary
April 25th : Mass with PIME group
April 26th : Bishop Council (Big)
April27th : Bassac + Mekong Monthly Meeting (at Champa)
April 28th : Teach at School of Faith
April 28th+29th: Vocation Sunday – Mass, prayers, conference at St Jospeh and Boeung toumpun

# រូបភាពប្រចាំខែ











**ព្រះសហគមន៍ភូមិភាគភ្នំពេញ**

**ព្រឹត្តិបត្រ ជីវិត**

អ្នកទទួលខុសត្រូវ: លោកអភិបាល អូលីវីយេ ឆ្មិតអឺស្លែរ

Tel: 023 212 462

Email: apostolicvicariate.phnompenh@gmail.com

ការិនិពន្ធ: ញឹប ញឿន

Email: markgnuen@gmail.com

ការិយាល័យផ្សព្វផ្សាយពត៌មានកាតូលិក

# ២៥ ផ្លូវ២៤២ បឹងព្រលឹត ៧មករា ភ្នំពេញ.

**Apostolic vicariate Phnom Penh**

**LIFE NEWSLETTER**

**Chairman:** Msgr. Olivier Schmitthaeusler.

**Tel:** 023 212 462

**Email:** apostolicvicariate.phnompenh@gmail.com

**Editor:** Gneb Gnuen

**Email:** markgnuen@gmail.com

**Catholic Social Communication**

#25, St 242, Boeung Prolit, 7 Makara, Phnom Penh.